
Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org

## 4.11 សាឡូម៉ូនទូលសូមប្រាជ្ញា

ដាវីឌបានឡើងជាស្តេចអស់រយៈពេលជាច្រើនឆ្នាំ។ គាត់បានគ្រប់គ្រងប្រជាជនយូដា (ជាផ្នែកនៃអ៊ីស្រា អែល) អស់រយៈពេល៧ឆ្នាំ។ បន្ទាប់មក គាត់បានគ្រប់គ្រងលើសាសន៍ អ៊ីស្រាអែល អស់រយៈពេល៣៣ឆ្នាំ។ ដាវីឌបានធ្វើឲ្យមានកំហុសជាច្រើន។ ជាច្រើនដង គាត់មិនបានស្តាប់បង្គាប់ព្រះអម្ចាស់។ ប៉ុន្តែ ព្រះអម្ចាស់ ទ្រង់ជ្រាបពីដួងចិត្តរបស់ដាវីឌ។ ទ្រង់ជ្រាបពេលដាវីឌធ្វើបាប។ ហើយទ្រង់ក៏ជ្រាបដែរ ពេលដែលដាវីឌសុំទោសទ្រង់ ចំពោះអំពើបាបរបស់គាត់។ ដាវីឌមានវ័យចាស់ណាស់ទៅហើយ។ គាត់ដឹងថាដល់ពេលដែលគាត់ត្រូវ ស្លាប់ហើយ។ កូនប្រុសរបស់គាត់ឈ្មោះសាឡូម៉ូន នឹងក្លាយជាស្តេចនៃសាសន៍អ៊ីស្រាអែល។ ដាវីឌបាននិយាយ ជាមួយសាឡូម៉ូន ក្នុងប៉ុន្មានថ្ងៃចុងក្រោយនេះ។

លោកនិយាយ ទៅកាន់សាឡូម៉ូនថា៖ «ចូរក្លាហានឡើង! រឹងមាំឡើង ដើរតាមព្រះ ហើយធ្វើអ្វីដែលទ្រង់បានប្រាប់ឯងឱ្យធ្វើចុះ។ ព្រះអម្ចាស់នឹងបង្ហាញផ្លូវសម្រាប់ឯងក្នុងជីវិតរបស់ឯង។ ត្រូវប្រាកដថា ធ្វើតាមវិធីនោះ។ ប្រសិនបើឯងធ្វើតាមអ្វី ដែលបិតាបានប្រាប់ ឯងនឹងបានលទ្ធផលល្អ នូវអ្វីដែលឯងនឹងធ្វើ និងកន្លែងណាដែលឯងនឹងទៅ។ ព្រះបានសន្យានឹងខ្ញុំថា ប្រសិនបើកូនប្រុសរបស់ខ្ញុំ ដើរដោយស្មោះត្រង់ជាមួយព្រះដោយអស់ពីដួងចិត្ត និងអស់ពីព្រលឹង នោះតែងតែនឹងមានស្តេចអ៊ីស្រាអែលមួយអង្គទៀត កើតចេញពីគ្រួសាររបស់យើង"។

ដាវីឌបានណែនាំសាឡូម៉ូនខ្លះៗ អំពីសត្រូវរបស់គាត់ និងអំពីមិត្ត របស់គាត់។ បន្ទាប់មកដាវីឌក៏បានសោយទិវង្គតទៅ។ សាឡូម៉ូនក៏បានឡើងសោយរាជ្យ ហើយគង់លើបល្ល័ង្ករបស់ឪពុកបន្ទាប់។ ការងារមួយរបស់ស្តេចសាឡូម៉ូន គឺសាងសង់ព្រះវិហារមួយ ដើម្បីឲ្យប្រជាជនអាចថ្វាយបង្គំព្រះអម្ចាស់បាន។ ប្រជាជននៅទីក្រុងនោះ មិនបានគោរពតាមការថ្វាយបង្គំរបស់ពួកគេទេ។ ដោយសារមិនមានព្រះវិហារដើម្បីថ្វាយបង្គំព្រះទេ ប្រជាជននឹងថ្វាយបង្គំតាមវិធីផ្សេងទៀត។ សាឡូម៉ូនបានធ្វើតាមការណែនាំរបស់ដាវីឌជាឪពុក អំពីការស្រឡាញ់ព្រះ និងដឹកនាំជីវិតល្អ លើកលែងតែគាត់បានថ្វាយបង្គំនៅកន្លែង ដែលមិនគាប់ព្រះហឫទ័យចំពោះព្រះអម្ចាស់ប៉ុណ្ណោះ។

នៅយប់មួយ ព្រះបានបង្ហាញខ្លួនឲ្យសាឡូម៉ូនឃើញនៅក្នុងសុបិន្តមួយ ព្រះអម្ចាស់មានព្រះបន្ទូលទៅកាន់សាឡូម៉ូនថា៖ «ចូរសុំអ្វីៗ ដែលឯងចង់បានចុះ នោះអញនឹងប្រទានឲ្យឯង»។ ស្តេចសាឡូម៉ូនបានឆ្លើយតបថា៖ «ព្រះអង្គបានសំដែងព្រះហឫទ័យមេត្តាករុណាដ៏ធំធេង ចំពោះអ្នកបំរើទ្រង់ គឺដាវីឌជាបិតារបស់ទូលបង្គំ។ បិតាទូលបង្គំបានស្មោះត្រង់នឹងទ្រង់ ហើយមានបេះដូងស្មោះស្ម័គ្រ ។ ព្រះអង្គបានសំដែងព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ដោយប្រទានបុត្រាមួយអង្គឲ្យស្នងរាជ្យបន្ត ។ ឥឡូវនេះ ព្រះអង្គជាព្រះនៃទូលបង្គំ ព្រះអង្គបានតែងតាំងទូលបង្គំជាអ្នកបំរើរបស់ព្រះអង្គ ឲ្យឡើងស្នងរាជ្យតពីបិតាទូលបង្គំគឺដាវីឌ ។ ប៉ុន្តែទូលបង្គំ គឺដូចជាក្មេងតូចម្នាក់ ។ ទូលបង្គំមិនដឹងថាត្រូវធ្វើអ្វី ដែលទូលបង្គំជាស្តេចត្រូវធ្វើនោះទេ ទូលបង្គំនៅទីនេះក្នុងចំណោមមនុស្ស ដែលទ្រង់បានជ្រើសរើស។ គឺមានមនុស្សច្រើនណាស់រាប់មិនអស់ទេ។

ដូច្នេះ អ្វីដែលទូលបង្គំពិតជាចង់បានពីទ្រង់ នោះគឺជាបេះដូងនៃប្រាជ្ញា គឺជាបេះដូងដែលស្តាប់តាមទ្រង់ ក្នុងការណែនាំដល់ទូលបង្គំ មុនពេលទូលបង្គំបានបើកមាត់ ។ ទូលបង្គំចង់ដឹកនាំប្រជាជនរបស់ទ្រង់ឲ្យបានល្អ។ ទូលបង្គំចង់ដឹងពីភាពខុសគ្នារវាងល្អ និងអាក្រក់នៅពេលពួកគេមានបញ្ហា។ គ្មាននរណាម្នាក់អាចដឹកនាំប្រជាជនដ៏រុងរឿងរបស់ព្រះអង្គ ដោយខ្លួនឯងបានឡើយ។ ព្រះទ្រង់បានសព្វព្រះហឫទ័យ នឹងសាឡូម៉ូនខ្លាំងណាស់។ ព្រះអម្ចាស់មានព្រះបន្ទូលមកគាត់ថា៖ «អ្នកមិនបានសុំទ្រព្យសម្បត្តិ ឬជីវិតដែលមានអាយុយឺនយូរ ឬឲ្យបំផ្លាញខ្មាំងសត្រូវឯងឡើយ។ តែឯងបានស្នើសុំដើម្បីអាចដឹកនាំប្រជាជន និងរដ្ឋាភិបាលនៅក្នុងប្រទេសនេះឱ្យបានល្អបំផុត។

ដូច្នេះ អញនឹងផ្តល់ឱ្យឯងនូវអ្វីដែលឯងបានស្នើសុំ គឺជាបេះដូងដែលមានប្រាជ្ញា និងការចេះដឹង។ ដោយសារតែនេះជាអ្វីដែលសំខាន់បំផុតសម្រាប់ឯង អញក៏នឹងផ្តល់ឱ្យឯងនូវទ្រព្យសម្បត្តិ និងការគាប់ចិត្តចំពោះប្រជាជនដែរ។ បើសិនជាឯងបន្តបម្រើអញជាព្រះនៃឯង ដូចដាវីឌជាបិតារបស់ឯងនោះ អញនឹងឲ្យឯងមានជីវិតយូរអង្វែង»។ បន្ទាប់មកសាឡូម៉ូន បានភ្ញាក់ពីសុបិន្តរបស់គាត់! គាត់ដឹងថាព្រះពិតជាបានមានបន្ទូលជាមួយគាត់ពិត មែន ។ **១ពង្សាវតារក្សត្រ ២ និង ៣**

## 4.11 សាឡូម៉ូនទូលសូមប្រាជ្ញា - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

### កំណត់សម្គាល់

1) ដាវីឌបានគ្រប់គ្រងលើសាសន៍អ៊ីស្រាអែល អស់រយៈពេលជាច្រើនឆ្នាំ។ ទ្រង់មានវ័យចាស់ណាស់ទៅហើយ។ ដល់ពេលដែលទ្រង់ត្រូវសោយទិវង្គតហើយ។ ទ្រង់បានមានបន្ទូលជាមួយកូនប្រុសរបស់ទ្រង់ឈ្មោះ សាឡូម៉ូន ក្នុងអំឡុងពេលនេះ ។ មិនយូរប៉ុន្មានសាឡូម៉ូននឹងឡើងសោយរាជ្យ។ ដាវីឌបានប្រាប់សាឡូម៉ូនឱ្យស្តាប់តាមព្រះអម្ចាស់ ហើយគាត់នឹងដឹងពីអ្វីដែលត្រូវធ្វើ ។ ទ្រង់បានប្រាប់គាត់ឱ្យមានភាពក្លាហាន និងរឹងមាំ ។
2) សាឡូម៉ូនមានភារកិច្ចត្រូវសាងសង់ព្រះវិហារ។ ព្រោះប្រជាជនត្រូវការកន្លែងថ្វាយបង្គំព្រះអម្ចាស់។ ពួកគេនឹងថ្វាយបង្គំព្រះតាមរបៀប ដែលមិនគាប់ព្រះហឫទ័យទ្រង់។ សូម្បីតែសាឡូម៉ូន ក៏ព្រះទ្រង់មិនសព្វព្រះហឫទ័យ ក្នុងការដែលគាត់បានថ្វាយបង្គំដែរ។
3) នៅយប់មួយ ព្រះទ្រង់បានមានបន្ទូលប្រាប់សាឡូម៉ូន។ ព្រះអម្ចាស់បានសួរសាឡូម៉ូននូវអ្វី ដែលគាត់ចង់បាន ជាងគេ។ សាឡូម៉ូនបានទូលប្រាប់ព្រះថា វាពិបាកណាស់ក្នុងការដឹកនាំប្រទេស នៃប្រជាជនរបស់ព្រះ ។ គឺមានប្រជាជនច្រើនណាស់។ សាឡូម៉ូនចង់ដឹកនាំប្រជាជនឲ្យបានល្អ។ សាឡូម៉ូនបានសុំបេះដូងឲ្យដូចជាបេះដូងរបស់ព្រះអម្ចាស់ ដែលអាចដឹកនាំប្រជាជនបាន ។ គាត់ក៏បានសុំប្រាជ្ញា ។
4) ព្រះទ្រង់សព្វព្រះហឫទ័យ នឹងសំណូមពររបស់សាឡូម៉ូន ។ ព្រះបានឆ្លើយតបនឹងសាឡូម៉ូន ហើយបានប្រាប់គាត់ថា ទ្រង់នឹងឲ្យពរដល់សាឡូម៉ូននូវអ្វី ដែលគាត់បានសុំ។ ប៉ុន្តែព្រះអម្ចាស់ក៏ប្រទានពរដល់គាត់នូវទ្រព្យសម្បត្តិ និងការពេញចិត្តពីប្រជាជនដែរ។ ហើយបើគាត់បម្រើព្រះអម្ចាស់ដូចជាដាវីឌ ដែលជាឪពុករបស់គាត់ដែរ នោះគាត់នឹងទទួលពរដោយមានអាយុវែង ។

**សំណួរ:**

1) តើអ្នកណានឹងឡើងស្នងតំណែងពីស្តេចដាវីឌលើអ៊ីស្រាអែល?
2) តើការងារអ្វីមួយសំខាន់ ដែលសាឡូម៉ូនត្រូវធ្វើ ក្នុងពេលឡើងជាស្តេច?
3) ព្រះបានសួរសាឡូម៉ូនក្នុងសុបិន្តអំពីអ្វី ដែលគាត់ចង់បានបំផុត ។ តើជាអ្វី?
4) ក្រៅពីប្រាជ្ញា តើព្រះអម្ចាស់បានប្រទានអ្វីដល់សាឡូម៉ូនទៀត?

**ចម្លើយ:**

1) សាឡូម៉ូនជាបុត្ររបស់ស្តេចដាវីឌ នឹងឡើងសោយរាជ្យបន្តពីស្តេចដាវិឌ លើអ៊ីស្រាអែល ។
2) ការងារសំខាន់មួយ ដែលសាឡូម៉ូនត្រូវធ្វើ គឺការសាសង់ព្រះវិហារសម្រាប់ប្រជាជន ដើម្បីថ្វាយបង្គំព្រះអម្ចាស់។
3) សាឡូម៉ូនបានទូលសូមព្រះអម្ចាស់ ឲ្យមានប្រាជ្ញាដើម្បីដឹកនាំប្រជាជនអ៊ីស្រាអែលទាំងមូល ។
4) ព្រះទ្រង់បានប្រទានឲ្យសាឡូម៉ូន នូវទ្រព្យសម្បត្តិ និងការពេញចិត្តពីប្រជាជនអ៊ីស្រាអែលថែមទៀត ។


Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org